**ប្រកាសបង្គាប់**

**មាត្រា១.**_ត្រូវតែងតាំងឯកឧត្តម **ព្រាប សិទ្ធត្រា** ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានឋានៈស្មើនឹង **អនុរដ្ឋលេខាធិការ** ។

**មាត្រា២.**_នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

**មាត្រា៣.**_ព្រះរាជក្រឹត្យនេះចូលជាធរមានថ្ងៃប់ ចាប់ពីថ្ងៃឡាយព្រះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

* * *

## II-រាជរដ្ឋាភិបាល

### ១_អនុក្រឹត្យ

### អនុក្រឹត្យលេខ ៦៩ អនក្រ.បក

### ស្តីពីការកំរិតការកិច្ចកំណត់ ការកិច្ចបន្ថែម ការកិច្ចថ្នាក់គួប និង ប្រាក់កំរៃ សំរាប់ការបង្រៀនក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ

### រាជរដ្ឋាភិបាល

_បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២

_បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

_បានឃើញ ព្រះរាជក្រមលេខ ០២ ន.ស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែ សំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែ សំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
-បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាល កម្ពុជា
-បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត ក្រសួងអប់រំ យុវជន និងកីឡា
-បានឃើញ ព្រះរាជក្រឹត្យព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦-៧-៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
-បានឃើញ អនុក្រឹត្យលេខ ៣៨ អនក្រ បក ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៦ ស្តីពីការបបម៉ោងកំណត់បន្ថែមនិងប្រាក់ម៉ោងបន្ថែម សំរាប់ការបង្រៀនក្នុងគ្រឹះស្ថានសិក្សាសាធារណៈ
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**សំរេច**

**មាត្រា១.-** ក-<u>ភារកិច្ចកំណត់</u> : គឺការងារដែលកំណត់ជាទូទៅ អោយគ្រូបង្រៀនម្នាក់ទទួលខុសត្រូវគ្រប់ផ្នែកបង្រៀនសិស្សមួយថ្នាក់ក្នុងថេរ:វេលាមួយពេល នៃកាលវិភាគប្រចាំថ្ងៃនៅក្នុងគ្រឹះស្ថានសិក្សា គឺមួយថ្ងៃបង្រៀន ៥ ម៉ោងសិក្សា (មួយសប្តាហ៍បង្រៀន ២៥ម៉ោងសិក្សា ) នៅពេលព្រឹក ឬនៅពេលរសៀល។ សំរាប់ថ្នាក់ទី៥ និងថ្នាក់ទី ៦ ភារកិច្ចកំណត់ក្នុងមួយថ្ងៃមាន ៥ម៉ោងកន្លះសិក្សា មួយសប្តាហ៍មាន ២៧ម៉ោង កន្លះសិក្សា។

ខ-<u>ភារកិច្ចបន្ថែម</u> : គឺការងារដែលបានប្រគល់បន្ថែមអោយគ្រូបង្រៀន មានភារកិច្ចកំណត់ម្នាក់ទទួលខុសត្រូវគ្រប់យ៉ាងក្នុងការបង្រៀនសិស្សមួយថ្នាក់ផ្សេងទៀត ក្នុងពេលផ្សេង តាមកាលវិភាគប្រចាំថ្ងៃនៅគ្រឹះស្ថានបឋមសិក្សា

គ-<u>ភារកិច្ចថ្នាក់គួប</u> : គឺការងារដែលប្រគល់អោយគ្រូបង្រៀនម្នាក់ទទួលខុសត្រូវគ្រប់យ៉ាងក្នុងការបង្រៀនសិស្សពីរក្រុម ឬ បីក្រុម ដែលមានកំរិតខុសៗគ្នា នៅក្នុងបន្ទប់រៀនតែមួយក្នុងថេរៈវេលាតែមួយ តាមកាលវិភាគទន់ភ្លន់ ដែលរៀបចំឡើងដោយគ្រូផ្ទាល់ និង បានឯកភាពពីនាយកសាលារៀន ព្រមទាំងមានការយល់ព្រមពីប្រធានការិយាល័យអប់រំ យុវជន និងកីឡា ស្រុក-ខ័ណ្ឌ ។

**មាត្រា២.-** មុខងាររបស់គ្រូ ដែលបំពេញភារកិច្ចបន្ថែម និងគ្រូថ្នាក់គួប :

ក-គ្រូដែលបំពេញភារកិច្ចបន្ថែម មានមុខងារធ្វើការរដ្ឋបាលគ្រប់យ៉ាងសំរាប់ថ្នាក់រៀន និងប្រើពេលបង្រៀនសិស្សតាមកាលវិភាគច្រើនជាង លើសគ្រូដែលបំពេញភារកិច្ចកំណត់ទូទៅ ដែលបង្រៀនតែមួយថ្នាក់ ។

ខ-គ្រូបង្រៀនថ្នាក់គួប មានមុខងារបំពេញការងាររដ្ឋបាលគ្រប់យ៉ាង សំរាប់ថ្នាក់រៀនច្រើនជាងតែប្រើពេលបង្រៀនតាមកាលវិភាគ ដូចគ្នានឹងគ្រូបំពេញភារកិច្ចកំណត់ទូទៅដែរ ។

**មាត្រា៣.-** អំពីប្រាក់ភារកិច្ចបន្ថែម :

ក-គ្រូបង្រៀនដែលត្រូវបានចាត់តាំងអោយបំពេញភារកិច្ចបន្ថែមក្នុងគ្រឹះស្ថានសិក្សាត្រូវ បានទទួលប្រាក់ភារកិច្ចបន្ថែម ស្មើនឹងប្រាក់បៀវត្សសរុបប្រចាំខែរបស់ខ្លួនចាប់ពីពេលដែលបានចាប់ផ្តើមរហូតដល់ពេលដែលសាមី ជនបានបញ្ចប់ភារកិច្ច ។

ខ-គ្រូបង្រៀនដែលត្រូវបានចាត់តាំងអោយបំពេញភារកិច្ចនៅថ្នាក់គួបក្នុងគ្រឹះស្ថានបឋមសិក្សា ត្រូវបានទទួលប្រាក់ភារកិច្ចបន្ថែមដូចតទៅ ÷

- ស្មើនឹងចំនួនប្រាក់ ៦០% នៃប្រាក់បៀវត្សសរុបប្រចាំខែរបស់ខ្លួន ចំពោះថ្នាក់គួបដែលមានពីរកំរិត ចាប់ពីពេលដែលបានចាប់ផ្តើមរហូតដល់ពេលសាមីខ្លួនបានបញ្ចប់ភារកិច្ច ។
- ស្មើនឹងចំនួនទឹកប្រាក់ ៨០% នៃប្រាក់បៀវត្សសរុបប្រចាំខែរបស់ខ្លួន ចំពោះថ្នាក់គួប ដែលមានបីកំរិតចាប់ពីពេលដែលបានចាប់ផ្តើម រហូតដល់ពេលដែលសាមីខ្លួនបានបញ្ចប់ភារកិច្ច ។

**មាត្រា៤.–** ការចាត់តាំងគ្រូបង្រៀនអោយបំពេញភារកិច្ចបន្ថែម ឬ ភារកិច្ចថ្នាក់គួបត្រូវស្នើដោយនាយកសាលាបឋមសិក្សា ដោយមានការឯកភាពពីប្រធានការិយាល័យអប់រំ ស្រុក-ខណ្ឌ និងមានការយល់ព្រមពីប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង ។

**មាត្រា៥.–** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៦.–** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចកិច្ចរៀងៗខ្លួន ។

**មាត្រា៧.–** អនុក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

**អ៊ុង ហួត** **ហ៊ុន សែន**

* * *

## អនុក្រឹត្យលេខ ៧០ អនក្រ.បក

## ស្ដីពីការបង្កើតគណៈកម្មាធិការជាតិអូឡាំពិក

## សំរាប់ជនពិការកម្ពុជា

* * *

## រាជរដ្ឋាភិបាល

–បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

–បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

–យោងតាមសំណើរបស់ អង្គការជនពិការកម្ពុជា

–ពិនិត្យសំណូមពរការងារ និង សមត្ថភាពរបស់មន្ត្រីរាជការ